

# ដំណាំល្ហុង

## ១- ការរៀបចំដីដាំល្ហុង:

- យើងត្រូវភ្ជួរហាលដីទុកចោលចំនួន ១ខែទៅ ១ ខែ កន្លះសិន ដើម្បីអោយងាប់សត្វល្អិតនិង ស្មៅ រលួយបានល្អ។ យើងត្រូវ ភ្ជួរដីមួយលើក ទៀត នៅពេលដែលជិតដាំកូនល្ហុង។
- យើងត្រូវទាញខ្សែអោយត្រង់ ដើម្បីងាយស្រួល ក្នុងការដាំដំណាំផ្សេងទៀត ក្រោមដើមល្ហុង។
- ចន្លោះពីដើមមួយទៅដើមមួយទៀត ប្រវែង ៣ ម៉ែត្រ។
- យើងត្រូវដោតបង្គោលចំណាំរណ្តៅដែលយើង វាស់រួចហើយ យកជីវែគ ចំនួន៥០០cc លាយ ទឹក ២០L មកបាញ់ឲ្យជោគ ចំបង្គោលរណ្តៅ ទំហំ២កឹត ៤ជ្រុង រួចទុករយៈពេល ៧ថ្ងៃ ទើប យើងកាប់រណ្តៅ។ មុនបាញ់ជី ត្រូវស្រោចទឹក ចំកន្លែងរណ្តៅអោយជោគសិន ទើបបាញ់ជី វែគ ដើម្បីអោយ ជីជ្រាបចូលទៅក្នុងដីបានល្អ វាធ្វើឲ្យដីផុសល្អសំបូរជីជាតិ និងសត្វជន្លេន។




## ២- ការដាំកូនល្ហុង:

- កាប់រណ្តៅដែលយើងស្រោចជីហើយ ទំហំ ២ តឹក ជំរៅ២តឹក កាប់បំផុសដីឲ្យម៉ត់ ដោយលាយ ជាមួយជីអាចម៍គោពុកល្អ។
- កូនល្ហុងអាយុពី១ខែកន្លះ ទៅ២ ខែមានប្រវែង មួយចង្អាមដៃ។ យើងត្រូវស្រោចទឹកឲ្យជោគ មុនយកទៅដាំ។
- យកថង់ចេញ ដោយកុំអោយបែកអាចម៍ដី និង ដាច់ឫសល្ហុងបណ្តាលឲ្យកូនល្ហុងងាប់បាន។
- កប់កូនល្ហុងអោយលិចដីកន្តោង រួចយកអាចម៍ ដីមកពូនសង្កត់អោយណែន បន្ទាប់មកស្រោច ទឹក អោយជោគ។
- ត្រូវស្រោចទឹកជារៀងថ្ងៃ នៅពេលល្ងាចអោយ ជោគល្មម។

## ៣- ការថែទាំដើមល្ហុង:

- ក្រោយដាំរួចយើងត្រូវបាញ់ថ្នាំការពារសត្វល្អិត ណ៉ាតូ" ក្នុងកំរិតប្រើ ៣០cc លាយជាមួយទឹក ១៦L បាញ់ទៅលើកូនល្ហុង ដើម្បីការពារកុំឲ្យ សត្វល្អិតស៊ី ឬកាត់ដើមល្ហុងចោល រៀងរាល់៥ ទៅ៧ថ្ងៃម្តងរហូតដល់កូនល្ហុងមានដើមប៉ុន ចង្កេះ។
- ដាំបានរយៈពេល ១ខែ បើមានស្មៅដុះជុំវិញ គល់ល្ហុង យើងត្រូវដកវាចេញឲ្យអស់ ពីព្រោះ បើទុកវាធ្វើឲ្យដើមល្ហុងមានការលូតលាស់យឺត។
- ក្រោយពេលសំអាតស្មៅរួចហើយយើងត្រូវជ្រុំ និងពូនគល់ល្ហុងម្តង។ រយៈពេល ២ខែបន្ទាប់ពី ដាំ ដើមល្ហុងមានកំពស់ត្រឹមជង្គង់ យើងត្រូវ ធ្វើស្មៅ តាមគល់ល្ហុង និងជ្រុំពូនគល់ម្តងទៀត ជាការស្រេច ព្រោះល្ហុងជិតចេញផ្កាហើយ។
- បន្ទាប់ពីជ្រុំពូនគល់លើកទី២រួចហើយ យើង ត្រូវ ស្រោចទឹកតាមគល់ល្ហុងអោយជោគសិន ទើប យើងយកជីវែគមកបាញ់ម្តងទៀត។បាញ់ ម្តងនេះគឺធ្វើឲ្យដើមល្ហុងធំរឹងមាំ ហើយជំនួយ



ដល់ការចេញផ្កា ធ្វើឲ្យផ្កាច្រើន មិនរុះ ហើយកាន់ផ្លែល្អ និង អោយល្ហុងមាន រសជាតិផ្អែមមួយ កំរិតទៀត។ ត្រូវលាយជី វែគ ១00cc ជាមួយ ទឹក ២0L ដូចមុនបាញ់ឲ្យសព្វត្រួយដើម និង គល់ល្ហុងអោយ សើមជោគ។

- រយះពេល ២ខែកន្លះទៅ ៣ខែល្ហុងចាប់ផ្តើមចេញផ្កាហើយ នៅពេលចេញផ្កា យើងអាចកំណត់ថាដើមមួយណាមានផ្លែវែង ហើយដើមមួយណាមានផ្លែខ្លី។ បើដើមណាមានផ្កាល្ហុងរាងទ្រវែងដូចកដបយើងទុកវា បើផ្កាល្ហុងមានរាងមូលខ្លីធំ យើងកាប់ដើមនោះចេញ នោះទើបល្ហុងក្នុងចំការមានសុទ្ធតែផ្លែវែងទាំងអស់។ ក្នុងមួយគុម្ព យើងទុកតែមួយដើមទេ។
- នៅពេលចេញក្តិប តែងតែមានត្រួយល្ហុងដុះចេញ តាមធាងនៃដើមល្ហុង។ យើងត្រូវបេះវាចេញ ដើម្បីអោយផ្លែល្ហុងរីកធំល្អ និងផ្លែច្រើន។



ផ្កាផ្លែមូលខ្លី



ផ្កាផ្លែវែង

## ៤- ការប្រមូលផល ៖

- រយះពេលពី ៥-៦ ខែយើងអាចប្រមូលផលបាន ចំពោះតែល្ហុងពូជផ្លែខ្លី។ បើចង់បេះទុំគឺយើង ទុករយះពេល៧ខែទើបអាចបេះទុំបាន។
- ពេលបេះផ្លែអស់ហើយយើងត្រូវបាញ់ជីវ៉ែគម្តងទៀតក្នុងកំរិតប្រើ ១00cc លាយជាមួយទឹក ២0L បាញ់តែគល់ល្ហុងទេ ហាមបាញ់លើផ្កា និង ក្តិបដែលអាចបណ្តាលអោយរុះផ្កានិងផ្លែក្តិប។ មុនពេលបាញ់ជីយើងត្រូវស្រោចទឹក អោយជោគគល់សិនទើបយើងបាញ់ជីនេះតាមក្រោយ។ ការបាញ់ជី ក្រោយពេលប្រមូលផល សំរាប់ជំនួយ ដល់ការចេញផ្កាក្តិប និងអោយផ្លែធំម្តងទៀត។

## ឯកសារពិគ្រោះ៖


- Traing module on fruit tree production, 2013 (គណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ នៅខេត្តតំបន់ពាយព្យ)
- បទពិសោធន៍ ជួប វិចិត្រ កសិករដាំល្ហុង, 2012 (ឃុំតាគ្រែ ស្រុកកំរៀង ខេត្តបាត់ដំបង)



សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោម:
លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧





ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម


# បទពិសោធន៍ជោគជ័យ ក្នុងការដាំល្ហុង របស់កសិករគំរូ




សហការផលិតដោយ៖
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ខេត្តសៀមរាប
ឆ្នាំ២០១៣